ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០៧......សហវ.ក.ឋអ

# សេចក្ដីណែនាំអនុវត្ត
## ស្ដីពី
## កាតព្វកិច្ច និងវិធីសាស្ត្របញ្ជូនទិន្នន័យព័ត៌មានអ្នកដំណើរតាមផ្លូវអាកាស

ការរៀបចំអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស (Global Travel Assessment System - GTAS) ដើម្បីបញ្ជូនទិន្នន័យព័ត៌មានអ្នកដំណើរជាមុន (Advance Passenger Information - API) និង កំណត់ត្រាឈ្មោះអ្នកដំណើរ (Passenger Name Record - PNR) សម្រាប់វិភាគហានិភ័យអ្នកដំណើរឆ្លងដែនតាមផ្លូវអាកាស ជាកាតព្វកិច្ចរបស់ប្រទេសជាសមាជិកអង្គការសហប្រជាជាតិក្នុងការចូលរួមអនុវត្តកម្មវិធីសន្តិសុខរបស់អង្គការគយពិភពលោក (World Customs Organization - WCO) ស្របតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ S/RES/2178 (2014) ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៤។

អនុលោមតាមការឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ស្ដីពីការអនុញ្ញាតដាក់អនុវត្តជាផ្លូវការ ក្នុងនាមរាជរដ្ឋាភិបាល នូវការប្រើប្រាស់ប្រព័ន្ធ GTAS និងអនុលោមតាមបញ្ញត្តិប្រកាសអន្តរក្រសួងលេខ ៥៥៤ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ស្ដីពីការដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ក្រុមការងារអន្តរក្រសួងអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស (**ក.ប.អ.**) សូមធ្វើការណែនាំ អំពីកាតព្វកិច្ចនិងវិធីសាស្ត្រក្នុងការអនុវត្តប្រព័ន្ធ GTAS ដល់បណ្ដា ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ ព្រមទាំងក្រុមហ៊ុនហោះហើរ ជាលក្ខណៈឯកជនពាណិជ្ជកម្មដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិ ចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម÷

### I- កាតព្វកិច្ចរបស់ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរ ជាលក្ខណៈឯកជនពាណិជ្ជកម្ម

អនុលោមតាមខ្លឹមសារប្រការ ៦ នៃប្រកាសអន្តរក្រសួងលេខ ៥៥៤ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្មដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចដូចខាងក្រោម÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

១. ត្រូវបញ្ជូនទិន្នន័យព័ត៌មានអ្នកដំណើរជាមុន (API) និងកំណត់ត្រាឈ្មោះអ្នកដំណើរ (PNR) របស់អ្នកដំណើរ និងក្រុមអាកាសយានិកក្នុងជើងហោះហើរ នៅពេលធ្វើដំណើរចាកចេញ ឬ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា

២. ត្រូវធ្វើការតភ្ជាប់ប្រព័ន្ធរបស់ខ្លួនមកកាន់ប្រព័ន្ធ GTAS និងធ្វើតេស្តដោយប្រើប្រាស់ទិន្នន័យសាកល្បង ដើម្បីធានាថាប្រព័ន្ធអាចផ្លាស់ប្តូរទិន្នន័យបាន ហើយទម្រង់ឯកសារដែលតម្រូវឱ្យប្រើប្រាស់អាចទទួលស្គាល់ដោយប្រព័ន្ធ GTAS បាន

៣. ការបញ្ជូនទិន្នន័យ API និង PNR មកកាន់ប្រព័ន្ធ GTAS ត្រូវធ្វើឡើងតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) ក្នុងទម្រង់ដែលបានកំណត់ និងតាមលំដាប់ពេលវេលា ដូចមានក្នុងសេចក្តីណែនាំ Cambodia API Operation Manual និង Cambodia PNR Operation Manual ភ្ជាប់ក្នុងឧបសម្ព័ន្ធមកជាមួយនេះ ដែលអាចរៀបចំកែសម្រួលពីពេលមួយទៅពេលមួយតាមការចាំបាច់។

## II- ភារកិច្ចរបស់ក្រុមការងារអន្តរក្រសួងអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស

ក្រុមការងារ **ក.ប.អ.** មានភារកិច្ចទទួលបន្ទុក÷

១. អនុវត្តខ្លឹមសារប្រកាសអន្តរក្រសួងលេខ ៥៥៤ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស

២. ផ្សព្វផ្សាយអំពីការដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធ GTAS ជូនដល់តួអង្គពាក់ព័ន្ធ

៣. ណែនាំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រៀបចំក្រុមការងារបច្ចេកទេសទទួលបន្ទុកអនុវត្តប្រព័ន្ធ GTAS

៤. ពិនិត្យនិងសម្រេចលើការចែករំលែកទិន្នន័យអ្នកដំណើរតាមផ្លូវអាកាស អនុលោមតាមបទប្បញ្ញត្តិជាធរមាន ដល់បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រើប្រាស់តាមសមត្ថកិច្ចរៀងៗខ្លួន។ ទិន្នន័យដែលត្រូវចែករំលែកទាំងនោះ ត្រូវរក្សាជាការសម្ងាត់ដោយភាគីស្នើសុំ។

## III- វិធីសាស្ត្របញ្ជូនទិន្នន័យអ្នកដំណើរតាមផ្លូវអាកាស

ទិន្នន័យព័ត៌មានអ្នកដំណើរជាមុន (API) និងកំណត់ត្រាឈ្មោះអ្នកដំណើរ (PNR) ត្រូវបញ្ជូនតាមរបៀបរុញ (Push Mode)។ ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្មដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកផ្តល់សេវាកម្មដែលក្រុមហ៊ុនបានប្រើប្រាស់ក្នុងការបញ្ជូនទិន្នន័យប្រសិនបើមាន និងត្រូវបញ្ជាក់ពីពិធីសារបច្ចេកទេស (Technical Protocol) ដែលត្រូវប្រើប្រាស់សម្រាប់បញ្ជូនទិន្នន័យ។



២ ត្ន

ប្រព័ន្ធ GTAS អាចអនុញ្ញាតឱ្យក្រុមហ៊ុនតភ្ជាប់ប្រព័ន្ធ ដោយប្រើប្រាស់វិធីសាស្ត្របញ្ជូនទិន្នន័យ និង ទម្រង់ឯកសារតាមស្តង់ដារអន្តរជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំទិន្នន័យ ដូចខាងក្រោម÷

១. ប្រព័ន្ធ GTAS អាចទទួលយកទិន្នន័យតាមវិធីសាស្ត្របញ្ជូនទិន្នន័យពីប្រព័ន្ធទៅប្រព័ន្ធ (System to System) មានដូចជា MQ Connector, Web Service, Sftp និង E-mail ជាដើម

២. ប្រព័ន្ធ GTAS អាចទទួលយកទិន្នន័យតាមទម្រង់ឯកសារ រួមមាន÷ ICAO - PNRGOV ជំនាន់ 11.1 ឡើងទៅ សម្រាប់ទិន្នន័យកំណត់ត្រាឈ្មោះអ្នកដំណើរ (PNR) និង UN/EDIFACT - PAXLST ជំនាន់ 02B ឡើងទៅ សម្រាប់ព័ត៌មានអ្នកដំណើរជាមុន (API)។

## IV- **ការពិន័យ**

ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម ដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ដែលខកខានក្នុងការអនុវត្ត តាមចំណុច I និងចំណុច III ខាងលើ ត្រូវរងការពិន័យរដ្ឋបាល និង/ឬទោសទណ្ឌផ្សេងទៀតតាមបទប្បញ្ញត្តិ ពាក់ព័ន្ធជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ សូមក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងបណ្តាក្រុមហ៊ុនអាកាសចរណ៍ ពាក់ព័ន្ធដូចខាងលើ សហការអនុវត្ត ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០២២

**ប្រធានក្រុមការងារអន្តរក្រសួង**

**អនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស**

**នួន ច័ន្ទរិទ្ធ**

**ចម្លងជូន÷**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា "ដើម្បីជូនជ្រាប"
- គ្រប់ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ